# ធម្មទេសនាយាចនគាថា

## ពាក្យសូមអារាធនាលោកអ្នកសម្តែងធម៌

សហម្បតីព្រហ្ម
ឱនបង្គំអារាធនា
សម្តេចព្រះភគវា
ដោយគាថាយ៉ាងនេះឯង ។
ព្រះពុទ្ធទ្រង់អនុកូល
ព្រមទទួលនឹងសម្តែង
ដោយតុណ្ហីភាពថ្លែង
តាមភាវៈគុណករុណា ។
ទើបក្រោកចាកទីនោះ
ភក្ត្រាឆ្ពោះព្រៃមិគទា
យាងចេញចរលីលា
ពីទីនោះដោយព្រះបាទ ។
ញុំាងសត្វចូលពុទ្ធចក្រ
មានបញ្ចវគ្គីយ៍ជាអាទិ៍
ឱ្យផឹកអម្រឹតជាតិ
រសនិព្វានតាមធម្មតា ។
ចាប់ដើមពីនោះឯង
ទ្រង់សម្តែងធម៌ទេសនា
ធ្វើពុទ្ធក្រឹត្យា
អស់វស្សាសែសិបប្រាំ ។
ពុំថយពុំបន្ធូរ
ប្រយោជន៍យូរអង្វែងឆ្នាំ
សម្រេចបុញ្ញកម្ម
ដល់សព្វសត្វទាំងភពត្រ័យ ។
ហេតុនោះឥឡូវនេះ
យើងខ្ញុំនេះសាទរក្រៃ
បពិត្រព្រះគុណថ្លៃ
សូមនិមន្តប្រោសទេសនា ។
អនុគ្រោះពួកបរិស័ទ
ដែលជាប់ខាត់ដោយមោហា
ឱ្យកើតមានបញ្ញា
ប្រាកដនាទីនេះហោង ។

វត្តធម្មារាម



ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៊ាន់ អ៊ុន** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣
វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ុន លី** ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២